00193575

**Declassified to Public**
**06 September 2012**

លេខ/ No: D25/5/18

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 27/05/2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Royaume du Cambodge**
**Nation Religion Roi**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27/05/2008
ម៉ោង (Time/Heure): 13:55
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 001/18-07-2007-ECCC-OCIJ**

# សេចក្តីសម្រេចទទួលស្គាល់មេធាវី
# Lawyer's Recognition Decision
# Décision d'accréditation d'avocat

យើង **យូ ប៊ុនឡេង** និង Marcel Lemonde សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ២៣ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច**

បានឃើញលិខិតចាត់តាំងរបស់លោកស្រី **ភឹង ស៊ុនថារី** ជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ ចំពោះលោកស្រីមេធាវី Silke Studzinsky និង លោកមេធាវី **ហុង គឹមសួន** ដែលទទួលបានការយល់ព្រមត្រឹមត្រូវរួចហើយក្នុងបញ្ជីមេធាវីដែលមានបំណងតំណាងជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក និង ដែលបានស្បថរួចហើយនៅចំពោះមុខសាលាឧទ្ធរណ៍ ជាមេធាវីរបស់ខ្លួន និង ការយល់ព្រមរបស់លោក-លោកស្រីមេធាវីនេះ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨។

## ហេតុដូច្នេះ

ទទួលស្គាល់ លោកស្រីមេធាវី Silke Studzinsky និង លោកមេធាវី **ហុង គឹមសួន** ជាសហមេធាវីការពារឲ្យដើមបណ្តឹងរដ្ឋប្បវេណីខាងលើសម្រាប់គោលបំណងនៃកិច្ចស៊ើបសួរនៅចំពោះមុខ អ.វ.ត.ក។

CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION* E.C.C.C * C.E.T.C.

ដោយសារលោក-លោកស្រីមេធាវី ត្រូវបានចាត់តាំងជាសហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះ សិទ្ធិនិងកាតព្វកិច្ចខាងក្រោម ត្រូវអនុវត្តចំពោះលោក-លោកស្រី

- **ការចូលរួមក្នុងកិច្ចការស៊ើបសួររបស់តុលាការ:** លោក-លោកស្រី ត្រូវបានអនុញ្ញាតឱ្យតំណាងកូនក្តីរបស់លោក-លោកស្រី នៅក្នុងកំឡុងពេលដែលពួកគេចូលរួមក្នុងនីតិវិធី ដូចមានចែងក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក.។

- **ការពិនិត្យពិគ្រោះសំណុំរឿង:** លោក-លោកស្រី មានសិទ្ធិពិនិត្យមើល និងថតចម្លងឯកសារពីសំណុំរឿងស៊ើបសួរច្បាប់ដើមណាដែលកូនក្តីរបស់លោក-លោកស្រី ជាដើមបណ្តឹងរដ្ឋប្បវេណី តាមរបៀបថតចម្លងជាក្រដាស ឬ តាមបែបអេឡិចត្រូនិក នៅក្នុងពេលម៉ោងធ្វើការ និងដោយគោរពទៅតាមល័ក្ខខ័ណ្ឌតម្រូវនៃកិច្ចដំណើរការល្អរបស់អ.វ.ត.ក។ ការពិនិត្យមើលសំណុំរឿងនេះ អាចរៀបចំ ដោយមានជំនួយរបស់អង្គភាពជនរងគ្រោះ ឬមន្ត្រីគ្រប់គ្រងសំណុំរឿង ប៉ុន្តែ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីសមត្ថកិច្ច។ លោក-លោកស្រី អាចថតចម្លង ឬស្នើសុំច្បាប់ថតចម្លងឯកសារដែលមាននៅក្នុងសំណុំរឿងតាមចំនួនសមរម្យ និង យកឯកសារទាំងនោះទៅពិភាក្សាជាមួយកូនក្តីរបស់លោក-លោកស្រី ប៉ុន្តែ លោក-លោកស្រី មិនអាចប្រគល់ឯកសារថតចម្លងទាំងនោះទៅឱ្យកូនក្តីរបស់លោក-លោកស្រី ឬ អ្នកដទៃបានឡើយ។

- **ការរក្សាការសម្ងាត់វិជ្ជាជីវៈ និងការសម្ងាត់នៃកិច្ចការតុលាការ:** តាមរយៈការចូលរួមរបស់កូនក្តីលោក-លោកស្រីក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី លោក-លោកស្រី និងកូនក្តីរបស់លោក-លោកស្រី នឹងអាចពិនិត្យពិគ្រោះព័ត៌មានសម្ងាត់ដែលមាននៅក្នុងសំណុំរឿង។ ប៉ុន្តែ មានតែចៅក្រមនិងព្រះរាជអាជ្ញា នៃ អ.វ.ត.ក ប៉ុណ្ណោះ ដែលអាចផ្សព្វផ្សាយព័ត៌មានទាំងនេះជាសាធារណៈបាន។ លោក-លោកស្រី ត្រូវចងដោយកាតព្វកិច្ចរក្សាការសម្ងាត់នៃកិច្ចស៊ើបសួររបស់តុលាការ និងក្រមវិជ្ជាជីវៈរបស់លោក-លោកស្រី ដោយមិនត្រូវផ្សព្វផ្សាយព័ត៌មានទាំងឡាយដែលលោក-លោកស្រីទទួលបានពីការពិនិត្យពិគ្រោះសំណុំរឿងនោះទេ។

- **ការដាក់តំកល់ឯកសារ:** នៅពេលដែលកូនក្តីរបស់លោក-លោកស្រី ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ រាល់ឯកសារផ្លូវការទាំងអស់ ត្រូវដាក់តំកល់តាមរយៈមន្ត្រីគ្រប់គ្រងសំណុំរឿងដូចមានកំណត់នៅក្នុងសេចក្តីណែនាំអនុវត្តអំពីការដាក់តំកល់ឯកសារ។ លោក-លោកស្រី នឹងទទួលបានការជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិកអំពីឯកសារដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ហេតុនេះ លោក-លោកស្រី ត្រូវផ្តល់ជូនអាសយដ្ឋានអ៊ីម៉ែលរបស់លោក-លោកស្រីទៅឱ្យក្រឡាបញ្ជីរបស់



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * JUGES D'INSTRUCTION

ការិយាល័យសហចៅក្រមស៊ើបអង្កេត សម្រាប់ប្រើក្នុងការទំនាក់ទំនងនេះ។ ការផ្តល់ជូនឯកសារជាក្រដាស អាចធ្វើបានតែក្នុងករណីណាដែលលោក-លោកស្រី មិនអាចមើលអ៊ីម៉ែលប៉ុណ្ណោះ។

វិធាន និងសេចក្តីណែនាំអនុវត្ត ទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី អាចពិនិត្យពិគ្រោះ និងថតចម្លងបាន តាមរយៈគេហទំព័ររបស់អង្គភាពជនរងគ្រោះ (http://www.eccc.gov.kh/)។ ប្រសិនបើ លោក-លោកស្រីត្រូវការការណែនាំបន្ថែមទាក់ទិននឹងការធ្វើជាតំណាងកូនក្តីរបស់លោក-លោកស្រី នៅក្នុងដំណើរការនីតិវិធីរបស់អ.វ.ត.ក សូមធ្វើទំនាក់ទំនងជាមួយនឹងអង្គភាពជនរងគ្រោះ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**

**Co-juges d'instruction**

CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

**MARCEL Lemonde** **យូ ប៊ុនឡេង**

យើង......................................ជា...............................បានប្រគល់សេចក្ដីសម្រេចនេះដល់

នៅថ្ងៃទី ខែ ឆ្នាំ ២០០៨ ។

**ហត្ថលេខាអ្នកទទួល** **ហត្ថលេខាអ្នកប្រគល់**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.